# អនុស្សរណៈស្តីពីការអភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ និងទីជំរករបស់វា នៅមហាសមុទ្រឥណ្ឌា និងអាស៊ីអគ្នេយ៍

បណ្តារដ្ឋជាហត្ថលេខី

*បានដឹងថា* បណ្តាភាវៈនៃអណ្តើកសមុទ្រចំនួនប្រាំមួយប្រភេទនៅក្នុងតំបន់ត្រូវបានចាត់បញ្ចូលក្នុងបញ្ជីប្រភេទកំពុងរងការគំរាមកំហែងរបស់អង្គការសហភាពអភិរក្សពិភពលោក(IUCN)ថាជាប្រភេទ ងាយរងគ្រោះថ្នាក់ កំពុងប្រឈមគ្រោះ-ថ្នាក់ ឬកំពុងប្រឈមគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរ ។

*បានកត់សំគាល់ថា* អណ្តើកសមុទ្របានទទួលអទិភាពសំរាប់សកម្មភាពអភិរក្សតាមរយៈការចុះក្នុងបញ្ជី ឬឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីការអភិរក្សប្រភេទសត្វព្រៃផ្លាស់ទីតាមរដូវ(CMS) អនុសញ្ញាស្តីពីពាណិជ្ជកម្មប្រភេទសត្វ និងរុក្ខជាតិកំពុងរងការគំរាមកំហែង(CITES) អនុសញ្ញាអាព្រិកស្តីពីការអភិរក្សធម្មជាតិ និងធនធានធម្មជាតិ និងអនុសញ្ញាស្តីពីការការពារ គ្រប់គ្រង និងអភិវឌ្ឍន៍បរិស្ថានសមុទ្រ និងតំបន់ឆ្នេរក្នុងតំបន់អាព្រិកខាងកើត និងបណ្តាពិធីសារពាក់ព័ន្ធនានា ។

*បានទទួលស្គាល់ថា* ការអភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា មានចែងជាពិសេសនៅក្នុងអនុសារណៈស្តីពីការអភិរក្ស និងការពារអណ្តើកសមុទ្រក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងកិច្ចព្រមព្រៀងស្តីពីបិតិកភ័ណ្ឌតំបន់ការពារធម្មជាតិនៃកោះអណ្តើក (TIHPA) ។

*បានទទួលស្គាល់ថា* បណ្តាកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត រួមទាំងអនុសញ្ញាសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS) បទបញ្ជានៃអង្គការស្បៀង និងកសិកម្មសហប្រជាជាតិ ស្តីពីការនេសាទប្រកបដោយការទទួលខុសត្រូវ អនុសញ្ញាអន្តរជាតិស្តីពីការរាំងស្កាត់ការបំពុលពីនាវាសមុទ្រ(MARPOL) និងអនុសញ្ញាស្តីពីជីវៈចំរុះ(CBD) សុទ្ធសឹងពាក់ព័ន្ធនឹងការអភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា ។

*បានដឹងថា* បណ្តាអង្គការប្រចាំតំបន់ដែលមានបច្ចុប្បន្ននេះ រួមទាំងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍(ASEAN) អង្គការប្រចាំតំបន់សំរាប់ការអភិរក្សបរិស្ថានសមុទ្រក្រហម និងឈូងសមុទ្រអាដិន(PERSGA) និងអង្គការប្រចាំតំបន់សំរាប់បរិស្ថានសមុទ្រ(ROPME) កំពុងអនុវត្តកម្មវិធីពាក់ព័ន្ធនឹងការអភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា ។

*បានទទួលស្គាល់ថា* អណ្តើកសមុទ្រផ្លាស់ទី និងធ្វើដំណើរយ៉ាងឆ្ងាយ ជាហេតុនាំឱ្យអត្ថិភាពនៃសត្វទាំងនេះអាស្រ័យនឹងសកម្មភាពអភិរក្សលើវិសាលភាពភូមិសាស្រ្តធំធេង និងនៅតាមបណ្តាទីជំរកប្លែកៗនៅក្នុងសមុទ្រ និងតំបន់ឆ្នេរ ។

*ដោយទទួលស្គាល់ថា* បណ្តាសកម្មភាពរបស់មនុស្សដែលអាចបង្កការគំរាមកំហែងលើបណ្តាភាវៈនៃអណ្តើកដោយផ្ទាល់ ដោយប្រយោល រួមមានទាំងការយកស៊ុត និងចាប់អណ្តើក សកម្មភាពភ្ញាស់ដោយពុំសមស្រប ការបំផ្លិចបំផ្លាញ ឬធ្វើឱ្យប្រែប្រួលទីជំរក ការអភិវឌ្ឍន៍នៅតំបន់ឆ្នេរ ការបំពុល សកម្មភាពនេសាទ វប្បកម្មក្នុងសមុទ្រ និងសកម្មភាពទេសចរណ៍ ។

*បានទទួលស្គាល់ថា* សារៈសំខាន់នៃការរួមបញ្ចូលសកម្មភាពអភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វាជាមួយបណ្តាសកម្មភាពពាក់ព័ន្ធនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនៃបណ្តារដ្ឋជាហត្ថលេខី រួមទាំងការអភិវឌ្ឍន៍នៅតំបន់ឆ្នេរ និងបណ្តាសកម្មភាពដែលប្រព្រឹត្តនៅក្នុងសមុទ្រ ។

*ដោយទទួលស្គាល់* ពីការទទួលខុសត្រូវរួមគ្នាក្នុងការអភិរក្ស និងគ្រប់គ្រងបណ្តាភាវៈអណ្តើកសមុទ្រ និងទីជំរករបស់វា ។

*បានទទួលស្គាល់* ពីសារៈសំខាន់នៃការបញ្ចូលបណ្តារដ្ឋទាំងអស់ក្នុងតំបន់ក៏ដូចជាបណ្តាអង្គការអន្តររដ្ឋាភិបាលពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នឯកជន នៅក្នុងកិច្ចសហប្រតិបត្តិការអភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ និងទីជំរករបស់វា។

*បានកត់សំគាល់* ពីបំណងក្នុងការរួមបញ្ចូលបណ្តារដ្ឋផ្សេងទៀត ដែលសកម្មភាពជាតិ ឬដែលមាននាវាកាន់ទង់រដ្ឋនោះធ្វើសកម្មភាព ដែលអាចប៉ះពាល់ដល់អណ្តើកសមុទ្រនៅក្នុងតំបន់ ក៏ដូចជាបណ្តារដ្ឋដែលអាចមានលទ្ធភាពរួមវិភាគទានជាធនធាន ឬជំនាញបច្ចេកទេស ដែលអាចជួយជំរុញការអនុវត្តន៍អនុសារណៈនេះ ។

*បានទទួលស្គាល់ថា* សកម្មភាពដោយឡែកពីគ្នា និងដែលមានការសំរបសំរួលគ្នាត្រូវតែអនុវត្តជាបន្ទាន់ ដើម្បីឆ្លើយតបនឹងការគំរាមកំហែងចំពោះបណ្តាភាវៈអណ្តើកសមុទ្រ និងទីជំរករបស់វា ។

*មានបំណង* ចាត់វិធានការណ៍ប្រកបដោយការសហការគ្នាតាមរយៈអនុសារណៈនេះ សំរាប់កិច្ចការពារ អភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ និងទីជំរករបស់វា ។

**និយមន័យ**

១. អណ្តើកសមុទ្រមានន័យថាប្រភេទណាមួយដូចមានរាយនៅខាងក្រោមនេះ :

| **ឈ្មោះជាភាសារអង់គ្លេស** | **ឈ្មោះជាភាសារខ្មែរ** | **ប្រភេទ** |
|---|---|---|
| Loggerhead turtle | អណ្តើកសមុទ្រក្បាលធំ | *Caretta caretta* |
| Olive ridley turtle | អណ្តើកល្មិចប្រផេះ | *Lepidochelys olivacea* |
| Green turtle | អណ្តើកល្មិចបៃតង | *Chelonia mydas* |
| Hawksbill turtle | អណ្តើកសមុទ្រចំពុះស្ទាំង | *Eretmochelys imbricata* |
| Leatherback turtle | អណ្តើកសមុទ្រស្បូកស្បែក | *Dermochelys coriacea* |
| Flatback turtle | | *Natator depressus* |

២. ទីជំរកមានន័យថា គ្រប់បណ្តាបរិស្ថានក្នុងទឹក និងលើគោក ដែលអណ្តើកសមុទ្រប្រើប្រាស់នៅដំណាក់កាលណាមួយនៃជីវិតរបស់វា ។

៣. តំបន់ មានន័យថាដែនទឹក និងរដ្ឋទាំងអស់ដែលនៅជាប់តំបន់ឆ្នេរនៃមហាសមុទ្រឥណ្ឌា និងអាស៊ីអគ្នេយ៍ និងសមុទ្រនានានៅជិតខាង និងលាតសន្ធឹងទៅភាគខាងកើតនៃច្រកសមុទ្រ Torres ។

៤. ស្ថានភាពអភិរក្សនៃអណ្តើកសមុទ្រ មានន័យថាឥទ្ធិពលសរុបទៅលើប្រភេទអណ្តើកសមុទ្រ ដែលអាចជះឥទ្ធិពលដល់របាយ និងភាពសំបូរនៃប្រភេទទាំងនោះសំរាប់រយៈពេលវែង ។

៥. ស្ថានភាពអភិរក្សនឹងចាត់ទុកថាមានអំណោយផលនៅពេលដែល :

ក) ទិន្នន័យអំពីឌីណាមិកនៃបណ្តាភាវៈបង្ហាញថាប្រភេទអណ្តើកសមុទ្រអាចរក្សាអត្ថិភាពរបស់ខ្លួនដោយខ្លួនឯង ដោយផ្អែកលើមូលដ្ឋាននៃរយៈពេលវែងជាចំណែកដែលទ្រទ្រង់អត្ថិភាពនៃប្រព័ន្ធអេកូឡូស៊ីរបស់វា ។

ខ) វង្វង់ភូមិសាស្ត្រនៃប្រភេទអណ្តើកសមុទ្រមិនមានសភាពរួមតូចនៅក្នុងពេលបច្ចុប្បន្ន និងមិនទំនងជានឹងរួមតូចនៅពេលអនាគតយូរអង្វែង ។

គ) សំរាប់ពេលបច្ចុប្បន្ន និងនៅពេលអនាគតខ្លីខាងមុខ មានទីជំរកក្នុងវិសាលភាពធំគ្រប់គ្រាន់សំរាប់ធានាតុល្យភាពនៃ បណ្តាភាវៈប្រភេទអណ្តើកសមុទ្រសំរាប់អនាគតយូរអង្វែង ។

ឃ) របាយ និងភាពសំបូរនៃប្រភេទផ្លាស់ទីតាមរដូវណាមួយ កើនឡើងដល់កំរិតខ្ពស់ ដែលសមស្របនឹងស្ថានភាពនៃអេកូស៊ីស្តែម និងដែលស្របតាមទស្សនៈស្តីពីការគ្រប់គ្រង សត្វព្រៃដោយឈ្លាសវៃ ។

**គោលបំណង**

គោលបំណងនៃអនុសារណៈនេះគឺដើម្បី ការពារ អភិរក្ស បំពេញ និងស្តារឡើងវិញនូវអណ្តើកសមុទ្រ និងទីជំរករបស់វាដោយផ្អែកលើភស្តុតាងវិទ្យាសាស្ត្រថ្មីៗ និងស្ថានភាពបរិស្ថាន ព្រមទាំងសេដ្ឋកិច្ចសង្គម និងវប្បធម៌នៃបណ្តារដ្ឋជាហត្ថលេខី ។

**សកម្មភាព**

ដើម្បីសំរេចបាននូវគោលបំណងនៃអនុស្សារណៈនេះ ប្រកបដោយការយោគយល់ និងសហប្រតិបត្តិការ បណ្តារដ្ឋជាហត្ថលេខីត្រូវ :

១. សហការគ្នាយ៉ាងជិតស្និទ្ធដើម្បីសំរេច និងរក្សាបាននូវស្ថានភាពអភិរក្សមានអំណោយផលសំរាប់អណ្តើកសមុទ្រ និងទីជំរករបស់វា ។

២. អនុលោមតាមធនធានចាំបាច់ដែលមាន ត្រូវប្រតិបត្តិតាមបណ្តូខដែលមានចែងក្នុងផែនការអភិរក្ស និងគ្រប់គ្រងដែលនឹងដាក់ជាឧបសម្ព័ន្ធនៃអនុស្សារណៈនេះ ។ ផែនការអភិរក្ស និងគ្រប់គ្រងត្រូវចែងពី កិច្ចការពារទីជំរកអណ្តើកសមុទ្រ គ្រប់គ្រងការប្រមូលផលដោយផ្ទាល់ និងការធ្វើពាណិជ្ជកម្ម កាត់បន្ថយការគំរាមកំហែង រួមទាំងអនុផលនេសាទ ការស្រាវជ្រាវ និងការអប់រំ ការផ្លាស់ប្តូរពត៌មាន និងការកសាងសមត្ថភាព ។

៣. តាមការចាំបាច់ ត្រូវពិនិត្យឡើងវិញ រៀបចំ កែសំរួល និងធ្វើឱ្យចុះសំរុងគ្នានូវបណ្តាច្បាប់ជាតិពាក់ព័ន្ធនឹងការអភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា និងត្រូវប្រើគ្រប់វិធីដើម្បីអនុវត្តច្បាប់ទាំងនោះឱ្យមានប្រសិទ្ធិភាព ។

៤. ពិចារណាផ្តល់សច្ចាប័ន ឬសុំចូលជាសមាជិកនៃបណ្តាកិច្ចព្រមព្រៀងអន្តរជាតិដែលពាក់ព័ន្ធជិតស្និទ្ធនឹងការអភិរក្សអណ្តើកសមុទ្រ និងទីជំរករបស់វា ដើម្បីបង្កើនកិច្ចការពារប្រភេទទាំងនេះនៅក្នុងតំបន់ ។

៥. បង្កើតលេខាធិការដ្ឋានដែលជួយធ្វើទំនាក់ទំនង លើកទឹកចិត្តឱ្យមានការរាយការណ៍ និងសំរបសំរួលសកម្មភាពរវាងនិងក្នុងចំណោម បណ្តារដ្ឋជាហត្ថលេខី ស្ថាប័នក្នុងអនុតំបន់ និងបណ្តារដ្ឋ និងអង្គការផ្សេងទៀតដែលមានចំណាប់អារម្មណ៍ ។ លេខាធិការដ្ឋានត្រូវចែកផ្សាយនូវរាល់របាយការណ៍ជាតិដែលខ្លួនបានទទួល ទៅគ្រប់រដ្ឋជាហត្ថលេខីនិងទៅគ្រប់ស្ថាប័នអនុតំបន់ដែលបង្កើតឡើង អនុលោមតាមវាក្យខ័ណ្ឌ៥ និង៦ នៃគោលការណ៍មូលដ្ឋាន និងត្រូវរៀបចំរបាយការណ៍ជាទៀងទាត់អំពីដំនើរការអនុវត្តផែនការ អភិរក្ស និងគ្រប់គ្រង និងត្រូវបំពេញមុខនាទីផ្សេងទៀតដែលអាចប្រគល់ឱ្យដោយបណ្តារដ្ឋជាហត្ថលេខី ។ លេខាធិការដ្ឋានត្រូវ តាំងនៅក្នុងការិយាល័យសមស្របណាមួយនៃស្ថាប័នជាតិ តំបន់ ឬអន្តរជាតិ តាមតែការឯកភាពជាទូទៅពីសំណាក់បណ្តារដ្ឋជាហត្ថលេខីនៅក្នុងកិច្ចប្រជុំលើកទីមួយរបស់ខ្លួន និងក្រោយពីបានពិចារណាលើរាល់សំណើរទាំងអស់ ។

៦. បង្កើតគណៈកម្មាធិការផ្តល់យោបល់វិទ្យាសាស្ត្រ បច្ចេកទេស និងច្បាប់សំរាប់បណ្តារដ្ឋជាហត្ថលេខីនីមួយៗ និងជាក្រុម ស្តីពីការអភិរក្ស និងគ្រប់គ្រងអណ្តើកសមុទ្រ និងទីជំរករបស់វានៅក្នុងតំបន់ ។ បណ្តារដ្ឋជាសមាជិកអាចស្នើតែងតាំងបុគ្គលដែលមានជំនាញផ្នែកជីវសាស្ត្រអណ្តើកសមុទ្រ ផ្នែកគ្រប់គ្រងធនធានសមុទ្រ ផ្នែកអភិវឌ្ឍន៏តំបន់ឆ្នេរសេដ្ឋកិច្ចសង្គម ច្បាប់ បច្ចេកវិទ្យានេសាទ និងផ្នែកនានាផ្សេងទៀតដែលពាក់ព័ន្ធ ជាសមាជិកនៃគណៈកម្មាធិការនេះ។ ចំនួនសមាជិក សមាសភាព និងលក្ខខ័ណ្ឌនៃការតែងតាំងគណៈកម្មាធិការផ្តល់យោបល់នឹងត្រូវកំនត់ដោយបណ្តារដ្ឋជាហត្ថលេខីនៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន ។

៧. ចាត់តាំងអាជ្ញាធរជាតិដែលមានសមត្ថភាពក្នុងការបំពេញនាទីជាកន្លែងទំនាក់ទំនងពិតមានរវាងបណ្តារដ្ឋជាហត្ថលេខីនិងអំពីសកម្មភាពក្នុងក្របខ័ណ្ឌអនុស្សារណៈនេះ និងត្រូវផ្តល់អាស័យដ្ឋានទំនាក់ទំនងលំអិតអំពីអាជ្ញាធរនេះ (និងអំពីការផ្លាស់ប្តូរណាមួយ) ជូនទៅលេខាធិការដ្ឋាន ។

៨. ផ្ញើជូនជាទៀតទាត់ទៅលេខាធិការដ្ឋាននូវរបាយការណ៍ស្តីពីការអនុវត្តន៍អនុស្សារណៈនេះ ។ ចន្លោះពេលនៃការផ្ញើរបាយការណ៍នេះ នឹងត្រូវកំនត់នៅក្នុងសម័យប្រជុំលើកទីមួយនៃបណ្តារដ្ឋជាហត្ថលេខី ។

៩. នៅក្នុងសម័យប្រជុំលើកទីមួយរបស់ខ្លួន ត្រូវវាយតំលៃពីវិសាលភាពនៃតំរូវការ និងលទ្ធភាពក្នុងការរកធនធានហិរញ្ញវត្ថុ រួមទាំង ការបង្កើតមូលនិធិពិសេសសំរាប់គោលបំណងនានា ដូចជា :

ក) បំពេញចំណាយចាំបាច់សំរាប់ដំណើរការរបស់លេខាធិការដ្ឋាន គណៈកម្មាធិការផ្តល់យោបល់ និងសកម្មភាពអនុវត្ត ក្នុងក្របខ័ណ្ឌនៃអនុស្សរណៈនេះ ។ និង

ខ) ជួយបណ្តារដ្ឋជាហត្ថលេខីដើម្បីអនុវត្តការទទួលខុសត្រូវរបស់ពួកគេក្នុងក្របខ័ណ្ឌនៃអនុសារណៈនេះ ។

<u>គោលការណ៍មូលដ្ឋាន</u>

១. អនុសារណៈនេះនឹងត្រូវចាត់ទុកជាកិច្ចព្រមព្រៀងតាមមាត្រា ៤ វាក្យខ័ណ្ឌ ៤ នៃអនុសញ្ញាអន្តរជាតិស្តីពីការអភិរក្ស ប្រភេទសត្វព្រៃផ្លាស់ទីតាមរដូវ ។ អនុសារណៈនេះនឹងចូលជាធរមាននៅថ្ងៃទីមួយក្នុងខែទីបី ក្រោយការចុះហត្ថលេខា របស់រដ្ឋទីពីរ ។ វានឹងត្រូវបើកចំហរដោយគ្មានកាលកំនត់ សំរាប់ការចុះហត្ថលេខាពីសំណាក់រដ្ឋផ្សេងៗទៀត ហើយនឹង ចូលជាធរមានសំរាប់បណ្តារដ្ឋទាំងនោះ នៅថ្ងៃទីមួយ នៃខែទីបីក្រោយការចុះហត្ថលេខារបស់របស់រដ្ឋទាំងនោះ ។

២. រដ្ឋជាហត្ថលេខីនិមួយៗត្រូវអនុវត្តអនុសារណៈនេះ តាមយុត្តាធិការរបស់ខ្លួនក្នុងក្របខ័ណ្ឌនៃ :

ក) បូរណៈភាពដែនដីរបស់ខ្លួននៅក្នុងតំបន់ ។

ខ) ដែលសមុទ្រក្នុងតំបន់ និងដែលស្ថិតក្រោមយុត្តាធិការរបស់ប្រទេសខ្លួន ។ និង

គ) នាវាកាន់ទង់ប្រទេសរបស់ខ្លួន និងដែលប្រតិបត្តិការនៅក្នុងតំបន់ ។

៣. ការអនុវត្តន៍អនុសារណៈនេះរួមទាំងផែនការអភិរក្ស និងគ្រប់គ្រងនឹងត្រូវទទួលការវាយតំលៃនៅក្នុងកិច្ចប្រជុំពេញអង្គ ដែលចូលរួមដោយតំណាងពីបណ្តារដ្ឋជាហត្ថលេខី និងបុគ្គល ឬអង្គការ ដែលមានសមត្ថកិច្ចបច្ចេកទេសពាក់ព័ន្ធនឹង ការអភិរក្សអណ្តើកសមុទ្រ ។ លេខាធិការដ្ឋានទទួលបន្ទុកការកោះប្រជុំបែបនេះ នឹងត្រូវរៀបចំដោយសហការជាមួយ រដ្ឋណាមួយក្នុងចំណោមបណ្តារដ្ឋជាហត្ថលេខីដែលមាននាទីជាម្ចាស់ផ្ទះសំរាប់កិច្ចប្រជុំ ។ ការប្រជុំបែបនេះគួរតែប្រព្រឹត្ត ទៅឱ្យបានជាទៀងរាល់ឆ្នាំ យ៉ាងហោចណាស់នៅក្នុងដំណាក់កាលដំបូង ។ ចន្លោះពេលនៃសម័យប្រជុំនេះអាចនឹង ត្រូវពិនិត្យ និងកែប្រែតាមការឯកភាពជាទូទៅពីសំណាក់ បណ្តារដ្ឋជាហត្ថលេខី នៅក្នុងកិច្ចប្រជុំពេញអង្គរបស់ខ្លួន ។

៤. អនុសារណៈនេះ រួមទាំងផែនការអភិរក្ស និងគ្រប់គ្រង អាចនឹងត្រូវកែសំរួលដោយមតិឯកភាពជាទូទៅពីសំនាក់ បណ្តារដ្ឋជាហត្ថលេខី ។ ក្នុងកាលៈទេសៈសមស្រប បណ្តារដ្ឋជាហត្ថលេខីត្រូវពិចារណាធ្វើវិសោធនកម្មអនុសារណៈនេះ ដើម្បីរក្សាសុពលភាពខាងផ្នែកច្បាប់ ។

៥. តាមរយៈការព្រមព្រៀងរវាងគ្នា បណ្តារដ្ឋជាហត្ថលេខីអាចបង្កើតផែនការគ្រប់គ្រងទ្វេភាគី ផែនការអនុតំបន់ ឬផែនការប្រចាំតំបន់ ដែលស្របគ្នាជាមួយអនុសារណៈនេះ ។

៦. បណ្តាសកម្មភាពអនុវត្តក្នុងក្របខ័ណ្ឌនៃអនុសារណៈនេះ នឹងត្រូវសំរបសំរួលដោយបណ្តារដ្ឋជាហត្ថលេខី និងជាមួយ បណ្តាស្ថាប័ន អនុតំបន់ នៅក្នុងតំបន់ ។

៧. អត្ថបទសំណៅដើមនៃអនុសារណៈនេះដែលមានជាភាសារ អារ៉ាប់ អង់គ្លេស និងភាសារបារាំង នឹងត្រូវតំកល់ទុក នៅឯលេខាធិការដ្ឋាននៃកម្មវិធីបរិស្ថានពិភពលោក/អនុសញ្ញាស្តីពីការអភិរក្សប្រភេទសត្វព្រៃផ្លាស់ទីតាមរដូវ ដែល មាននាទីជាកន្លែងតំកល់ឯកសារ ។ ក្នុងករណីដែលមានភាពមិនចុះសំរុងគ្នា អត្ថបទជាភាសារអង់គ្លេសនឹងត្រូវប្រើប្រាស់ ជាឯកសារគោល ។

៨. អនុលោមតាមច្បាប់អន្តរជាតិ ពុំមានប្រការណាមួយក្នុងអនុសារណៈនេះហាមឃាត់មិនឱ្យបណ្តារដ្ឋជាហត្ថលេខីចាត់ វិធានការណ៍នៅក្នុងប្រទេសរបស់ខ្លួន តឹងរ៉ឹងជាងប្រការដែលមានចែងក្នុងផែនការអភិរក្ស និងគ្រប់គ្រងឡើយ ។

៩. អនុសារណៈនេះនឹងនៅជាធរមានគ្មានកាលកំណត់ ហើយបណ្តារដ្ឋជាហត្ថលេខីអាចមានសិទ្ធិផ្តាច់ខ្លួនចេញពី អនុសារណៈនេះ ដោយត្រូវធ្វើសេចក្តីជូនដំណឹងទៅកន្លែងតំកល់ឯកសារជាមុនក្នុងរយៈពេលមួយឆ្នាំ ។